Education
Public Schools

Ride a bicycle safely




## ព័ត៌មានអំពីសុវត្ថិភាពតាមដងផ្លូវ

លោកអ្នកទទួលខុសត្រូវចំពោះសុវត្ថិភាពរបស់កូនលោកអ្នក នៅពេលកូនលោកអ្នកធ្វើដំណើរទៅកាន់និងវិលត្រឡប់ពីសាលារៀន។

# ជិះកង់ដោយមានសុវត្ថិភាព

ដោយសារតែកុមារតូចៗកំពុងបង្កើតជំនាញដែលត្រូវការដើម្បីជិះដោយខ្លួនឯងនៅឡើយ កន្លែងមានសុវត្ថិភាពបំផុតដើម្បីជិះកង់ ជិះscooters និង skateboards គឺក្នុងរង្វង់កន្លែងដែលមានរបង។

នៅពេលជិះ កុមារគួររក្សាចម្ងាយពីរថយន្តនិងផ្លូវរថយន្តបើកចេញចូលផ្ទះ រហូតដល់គេមានអាយុយ៉ាងតិច 10ឆ្នាំ។ នៅពេលដែលកុមារកំពុងរៀនជិះកង់ ការជិះ ឬដើរអមជាមួយកុមារ គឺជាការសំខាន់ ដើម្បីនិយាយពន្យល់អំពីរបៀបធ្វើជាអ្នកជិះកង់ដោយសុវត្ថិភាព។

កុមារមានអាយុចាប់ពី 10 ទៅ 12ឆ្នាំ គួរជិះកង់ឆ្ងាយពីផ្លូវមមាញឹក។

កុមារមានអាយុតិចជាង 16ឆ្នាំ និង ជនពេញវ័យដែលជិះកង់អមដំណើរ និងមើលខុសត្រូវកុមារ អាចជិះលើផ្លូវដើរបាន លើកលែងតែមានសញ្ញាហាមឃាត់ជាក់លាក់នូវការជិះកង់។

### បង្ហាត់កូនលោកអ្នកឱ្យធ្វើជាអ្នកជិះកង់មានសុវត្ថិភាព ដោយជានិច្ចជាកាលប្រាប់កូនឱ្យ៖

- ធ្វើតាមបទបញ្ញត្តិជិះកង់តាមផ្លូវ ដោយមានរួមទាំង៖
  - ជិះនៅចំហៀងខាងឆ្វេងផ្លូវដើរ
  - ផ្តល់អ្នកថ្មើរជើងនូវសិទ្ធិប្រើផ្លូវ នៅតាមផ្លូវដើរ
  - ប្រុងប្រយ័ត្នចំពោះរថយន្តដែលបើកចេញចូលផ្លូវបើកចេញចូលផ្ទះ
- ពាក់មួកសុវត្ថិភាពសម្រាប់ជិះកង់ដែលមានទំហំខ្នាតត្រឹមត្រូវ – ជាតម្រូវការរបស់ច្បាប់
- ស្លៀកពាក់ខោអាវមានពណ៌ភ្លឺខ្លាំង ដូចជាអាវកាក់ពណ៌ឆើត ដើម្បីឱ្យអ្នកប្រើផ្លូវឯទៀតអាចមើលឃើញកុមារ។

### ដើម្បីទទួលជំនួយបន្ថែម

សូមអានកម្មវិធីអប់រំអំពីសុវត្ថិភាពនៅតាមផ្លូវរបស់ក្រសួង នៅឯ https://education.nsw.gov.au/road-safety-education ឬបើកមើល https://education.nsw.gov.au ហើយស្វែងរកមើលការអប់រំអំពីសុវត្ថិភាពនៅតាមផ្លូវ។

**ចំពោះកុមារធំៗ ត្រូវគិតឱ្យបានម៉ត់ចត់អំពីចំណុចដូចតទៅ នៅពេលវាយតម្លៃសមត្ថភាពរបស់កុមារទាំងនេះក្នុងការជិះកង់ដោយខ្លួនឯង៖**

- តើផ្លូវធ្វើដំណើរមានសុវត្ថិភាពយ៉ាងណាដែរ?
- តើកុមារមានជំនាញជិះកង់យ៉ាងណាដែរ?
- តើកុមារដឹងហេតុការណ៍ជុំវិញខ្លួនយ៉ាងណាដែរ នៅក្នុងមជ្ឈដ្ឋានចរាចរណ៍?
- តើកុមារអាចគ្រប់គ្រងដោះស្រាយបានល្អយ៉ាងណាដែរនូវគ្រោះថ្នាក់ដែលមិនបានរំពឹងទុក?

សាលារៀនរបស់កូនលោកអ្នកនឹងមានបទដ្ឋានអំពីសិស្សដែលយកកង់ចូលទៅកាន់បរិវេណសាលារៀន។ ធ្វើឱ្យច្បាស់ថា កូនលោកអ្នកធ្វើតាមបទដ្ឋានទាំងនេះគ្រប់ពេល។

